**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៨០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការអនុវត្តន៍អាករលើការស្នាក់នៅ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៩ ស្តីពីអាករលើតំលៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**សម្រេច :**

**ប្រការ ១.-**

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ អាករលើការស្នាក់នៅត្រូវបានកំណត់ និងប្រមូលលើការស្នាក់នៅក្នុងសណ្ឋាគារ ស្ថិតនៅក្នុងរបបកំណត់ពន្ធស្វ័យប្រកាស (របបពិត) និងរបបម៉ៅការ សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាខេត្ត-ក្រុង ។

**ប្រការ ២.-**

សំរាប់គោលដៅនៃប្រកាសនេះ ពាក្យ "សណ្ឋាគារ" សំដៅដល់មូលដ្ឋានផ្គត់ផ្គង់សេវាស្នាក់នៅមានលក្ខណៈជាបន្ទប់ គ្រែ និងមានផ្តល់នូវសម្បទា និងសេវាផ្សេងៗទៀត ទៅតាមប្រភេទនៃមូលដ្ឋានសេវាស្នាក់នៅនីមួយៗ ដូចជា :

ក. **សណ្ឋាគារ** (Hotel) : ជាអាគារមានច្រើនជាន់ ដែលមានទីតាំងស្ថិតនៅក្នុងទីប្រជុំជនជាយក្រុង ឬតំបន់រមណីយដ្ឋានទេសចរណ៍ និងអាចផ្គត់ផ្គង់នូវសេវាពេញលេញដល់ភ្ញៀវ ដូចជា : សេវាស្នាក់នៅ ភោជនីយដ្ឋាន សេវាបំរើអាហារភ្ញៀវដល់បន្ទប់ សេវាបោកគក់ ហាងលក់ទំនិញ និងកន្លែងរៀបចំពិធីជប់លៀង សាលប្រជុំ និងចំណតរថយន្ត ។

ខ. **សណ្ឋាគារអាផាតម៉ិន** (Hotel Apartment) : ជាសណ្ឋាគារមានបន្ទប់ស្នាក់នៅ និងបន្ទប់ស្វ៊ីត (Suite) ដែលបំពាក់គ្រឿងសង្ហារិម សំភារៈបរិក្ខារ និងផ្គត់ផ្គង់នូវសេវាដូចសណ្ឋាគារដែរ ។ បន្ទប់ស្វ៊ីតមានបំពាក់គ្រឿងសំភារៈ ផ្ទះបាយនិងមានបន្ទប់សំរាប់ភ្ញៀវ ។ ភ្ញៀវអាចស្នាក់នៅរយៈពេលខ្លី និងវែង ។

គ. **សណ្ឋាគារស្វ៊ីត** (Suite Hotel) : ជាសណ្ឋាគារដែលមានបន្ទប់ស្នាក់នៅទាំងអស់សុទ្ធតែជាបន្ទប់ស្វ៊ីត ។

ឃ. **សណ្ឋាគាររីសត** (Resort Hotel) : ជាសណ្ឋាគារ ដែលសង់ក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ ស្ថិតនៅឆ្ងាយពីទីប្រជុំជន មានកន្លែងសំរាប់លំហែកាយសំរាកយកខ្យល់អាកាស មានផ្តល់នូវម្ហូបអាហារឬភេសជ្ជៈចំពោះភ្ញៀវដែលមកស្នាក់នៅនិងកំសាន្ត ដូចជា: វាយកូនគោល វាយតេននីស ស្ទូចត្រី ជិះសេះ ។ល។ តំលៃបន្ទប់អាចគិតរួមបញ្ចូលទាំងអាហារ ។

ង. **ម៉ូតែល** (Motel) : ជាអាគារមានមួយ ឬពីរជាន់ ស្ថិតនៅតំបន់ជាយក្រុង ឬតាមបណ្តោយផ្លូវសំខាន់ៗ ផ្តល់នូវសម្បទា និងសេវាមានកំរិតសំរាប់ភ្ញៀវដែលចូលមកស្នាក់នៅ ។ មានភោជនីយដ្ឋានសាមញ្ញតូចមួយ (Snake Bar) សំរាប់ទទួលភ្ញៀវ មានចំណតរថយន្តធំទូលាយ និងអាចមានផ្គត់ផ្គង់នូវសេវាសំរាប់កំសាន្តមួយចំនួន ។

ច. **ឡូជ** (Lodge) : ជាអាគារមានពីរ ឬច្រើនជាន់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់សំរាកវិស្សមកាល ។ ជាទូទៅមានបំរើសេវាម្ហូបអាហារ និងភេសជ្ជៈ មានចំណតរថយន្ត ព្រមទាំងផ្គត់ផ្គង់សេវាមានកំរិតដល់ភ្ញៀវដែលចូលមកស្នាក់នៅ ។

ឆ. **ប៊ីងកាឡូ** (Bungalow): មានអាគារជាភូមិគ្រឹះដាច់ៗពីគ្នា មានមួយជាន់ និងអាចមានច្រើនយូនីត (Unit) ក្នុងអាគារតែមួយ ។ យូនីតនីមួយៗ មានបន្ទប់ដេកមួយ ឬច្រើន មានបន្ទប់ទទួលភ្ញៀវដាច់ដោយឡែក មានផ្ទះបាយ មានចំណតរថយន្ត ព្រមទាំងផ្គត់ផ្គង់សេវាមានកំរិតដល់ភ្ញៀវដែលចូលមកស្នាក់នៅ ។

ជ. **ផ្ទះសំណាក់ ឬផ្ទះភ្ញៀវ** (Guest House) : ជាអាគារដែលមានមួយជាន់ ឬពីរជាន់ បំពាក់សំភារៈ និងផ្គត់ផ្គង់សេវាមានកំរិត អាចទទួលភ្ញៀវបានគ្រប់ប្រភេទ ។

ឈ. **កន្លែងបោះជំរុំទេសចរណ៍** (Tourist Camping): ជាកន្លែងដែលបានបង្កើតឡើង នៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ មានហេដ្ឋារចនាសម្ព័ន្ធ និងសេវាស្នាក់នៅចាំបាច់មួយចំនួន ដើម្បីបំរើភ្ញៀវ ។

ញ. ទីកន្លែងផ្តល់សេវាស្នាក់នៅដ៏ទៃទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល ទោះជាឱ្យ ឬដាក់ឈ្មោះថាជាអ្វីក៏ដោយ ។

ពាក្យ "សណ្ឋាគារ" នេះ មិនរួមបញ្ចូលផ្ទះជួល ឬផ្ទះល្វែងជួលរយៈពេលខ្លី និងរយៈពេលវែងទេ ។

**ប្រការ ៣.-**

អាករលើការស្នាក់នៅ ត្រូវបានកំណត់យកតាមអត្រា ២ ភាគរយ លើថ្លៃបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារ ដោយរួមបញ្ចូលទាំងពន្ធ-អាករ និងបន្ទុកសេវាផ្សេងៗ (Service Charge) លើកលែងតែអាករលើការស្នាក់នៅខ្លួនឯង និងអាករលើតម្លៃបន្ថែម ។ ម្ចាស់សណ្ឋាគារ ឬអ្នកតំណាងមានកាតព្វកិច្ចប្រមូលប្រាក់អាករនេះពីភ្ញៀវ និងបង់ជូនរដ្ឋបាលសារពើពន្ធ ។

**ប្រការ ៤.-**

១. វិធាននៃការបង់ប្រាក់អាករត្រូវបានកំណត់ដូចខាងក្រោម :

- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់អាករប្រចាំខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្គត់ផ្គង់ ។
- អ្នកជាប់ពន្ធតាមរបបម៉ៅការ ត្រូវបង់ប្រាក់អាករនេះជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្គត់ផ្គង់ ។

២. ពេលផ្គត់ផ្គង់សេវាស្នាក់នៅត្រូវបានកំណត់ដូចខាងក្រោម :

ក. អាករលើការស្នាក់នៅត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់សេវាស្នាក់នៅ ។ ការផ្គត់ផ្គង់សេវាស្នាក់នៅ គឺជាពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញ

វិក្កយបត្រ ឬជាពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងបានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះ ត្រូវបានចេញមុនពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាង ត្រូវចេញវិក្កយបត្រ ។ ម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញវិក្កយបត្រអាករ លើការស្នាក់នៅយ៉ាងយឺតបំផុត ៧ថ្ងៃ ក្រោយពីការបំពេញសេវាស្នាក់នៅត្រូវបញ្ចប់ឬក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើង មុនការបំពេញសេវាលើការស្នាក់នៅ ។

ខ. ក្នុងករណីសេវាលើការស្នាក់នៅ ត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺជាពេលដែលសេវាផ្គត់ផ្គង់ត្រូវបានបំពេញរួចរាល់ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រូវយកមកអនុវត្តចំពោះអាករលើការស្នាក់នៅនេះ។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥ នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥

**គាត ឈន់**

**ចម្លងជូន** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។